00702803

E87/3

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 06 / 2011
ម៉ោង (Time/Heure) : 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះសាលាដំបូង**

**ជូនចំពោះ:** ក្រុមមេធាវីការពារក្តី អៀង សារី និងភាគីទាំងអស់នៃសំណុំរឿង ០០២

**កាលបរិច្ឆេទ:** ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

**សាធារណៈ / Public**

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី

យោងតាមសំណើលេខ E87 ក្រុមរបស់លោកបានស្នើសុំការបញ្ជាក់ទៅលើចំណុចមួយចំនួនដូចជា៖ ក) រយៈពេលសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបើកសវនាការ ដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងផ្តល់ឲ្យក្រុមមេធាវីការពារក្តីនីមួយៗ និង ខ) បញ្ហាថាតើក្រុមមេធាវីការពារក្តីមានសិទ្ធិទាក់ទងបុគ្គលដែលអាចជាសាក្សី និងអ្នកជំនាញនៅមុនពេលសវនាការដែរ ឬទេ។

អង្គជំនុំជម្រះសូមជម្រាបថា ការធ្វើសេចក្តីសន្និដ្ឋានបើកពុំមែនជាផ្នែកមួយនៃកិច្ចសវនាការបឋមនាពេលខាងមុខនេះឡើយ ប៉ុន្តែជាកិច្ចមួយនៅមុនពេលនៃការចាប់ផ្តើមសវនាការលើអង្គសេចក្តី។ អង្គជំនុំជម្រះពុំទាន់ប្រកាសអំពីកាលបរិច្ឆេទសវនាការលើអង្គសេចក្តីនៅឡើយទេ ប៉ុន្តែអង្គជំនុំជម្រះនឹងប្រកាសឲ្យដឹងនៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការ ដែលនឹងចេញនាពេលសមស្របខាងមុខ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចបញ្ជាក់ថា រយៈពេល ១០ ម៉ោងដែលក្រុមរបស់លោកបានស្នើសុំសម្រាប់ធ្វើការឆ្លើយតបដោយសង្ខេបនោះ គឺជារយៈពេលច្រើនលើសលប់ប្រៀបធៀបទៅនឹងរយៈពេលដែលអង្គជំនុំជម្រះគ្រោងនឹងផ្តល់ឲ្យក្រុមមេធាវីការពារក្តីនីមួយៗ។

ពាក់ព័ន្ធទៅនឹងសំណើទីពីរ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តី អៀង សារី ពុំបានផ្តល់ជូនអង្គជំនុំជម្រះនូវបញ្ជីឈ្មោះសាក្សី តាមដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (ឯកសារលេខ E9) របស់អង្គជំនុំជម្រះឡើយ ហើយពេលវេលាកំណត់ក្នុងការដាក់បញ្ជីឈ្មោះនេះបានហួស តាំងពីពេលនោះមកម្ល៉េះ។ ដូច្នេះ តាមរយៈសំណើរបស់លោក អង្គជំនុំជម្រះពុំអាចយល់ច្បាស់ឡើយថាតើសាក្សី និងអ្នកជំនាញណាខ្លះដែលលោកមានបំណងចង់ទាក់ទង និងគោលបំណងនៃការទាក់ទងនេះ។ ក្នុងកិច្ចប្រជុំរៀបចំសវនាការ

អង្គជំនុំជម្រះបានជម្រាបដល់ភាគីអំពីកម្មវត្ថុនៃសវនាការបឋមនេះ ហើយអង្គជំនុំជម្រះ បានបញ្ជាក់ថាបញ្ជីឈ្មោះបុគ្គលដែលអាចជាសាក្សី និងអ្នកជំនាញដែលភាគីបានដាក់ជូនអង្គជំនុំជម្រះ នឹងត្រូវលើកយកទៅពិភាក្សានៅក្នុង សវនាការបឋម (ឯកសារលេខ E86)។ អង្គជំនុំជម្រះស្នើក្រុមមេធាវីការពារក្តី អៀង សារី ពិនិត្យមើលអនុស្សរណៈរបស់អង្គជំនុំជម្រះ E93 ចុះ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ដែលបានជូនព័ត៌មានជាក់លាក់ដល់ ភាគីពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះក្នុងការពិចារណាទៅលើបុគ្គលដែលអាចជាសាក្សីនៅក្នុងសវនាការបឋម។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលបានស្នើសុំសិទ្ធិក្នុងការទាក់ទងសាក្សីដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់ភាគីដទៃ ឬបុគ្គលផ្សេងទៀតដែលខ្លួនចាត់ទុកថាអាចធ្វើជាសាក្សីថ្មី។

បន្ថែមពីលើនេះ អង្គជំនុំជម្រះបានឯកភាពតាមសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី (សំណើលេខ E71/1/2) ដែលបានស្នើសុំការដាក់ចំណាត់ថ្នាក់ឡើងវិញទៅលើសំណើ E71 ថាជាឯកសារសាធារណៈ។ អង្គជំនុំជម្រះនឹងដាក់ចំណាត់ថ្នាក់សំណើខាងលើនេះឡើងវិញនាពេលឆាប់ៗខាងមុខនេះ និងជូនដំណឹងនៅក្នុងសំណុំរឿង។

នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំលេខ E87 និង E71/1/2។